

# ព្រះយេស៊ូវបានសន្យាថានឹងប្រទានការលួងលោមដល់យើង

ព្រះយេស៊ូវគ្រីស្ទបានដឹងថា ពួកសិស្សរបស់ទ្រង់នឹងត្រូវការការលួងលោមក្រោយពេលទ្រង់សុគតទៅ ។ ដូច្នេះ ទ្រង់បានបង្រៀនពួកគេអំពីព្រះវិញ្ញាណបរិសុទ្ធ ។ ទ្រង់បានសន្យាថា ព្រះវិញ្ញាណបរិសុទ្ធនឹងលួងលោមដល់ពួកគេ ហើយគង់នៅជាមួយពួកគេជានិច្ច ។ ព្រះនាមមួយរបស់ព្រះវិញ្ញាណបរិសុទ្ធគឺអង្គលួងលោមចិត្ត ។ នៅពេលយើងសោកសៅ ឬភ័យខ្លាច នោះព្រះវិញ្ញាណបរិសុទ្ធអាចជួយយើងឲ្យចងចាំនូវសេចក្ដីស្រឡាញ់របស់ព្រះយេស៊ូវគ្រីស្ទបាន ។●

ប្អូនអាចអានអំពីដំណើររឿងនេះនៅក្នុង យ៉ូហាន ១៤:១, ១៦–១៨, ២៦ ។

## ខ្ញុំអាចលួងលោមមនុស្សដទៃ

- តើអ្នកណាជាមនុស្សម្នាក់ដែលត្រូវការការលួងលោម ?
- សូមអធិស្ឋាន ហើយរៀបផែនការមួយដើម្បីជួយពួកគេ ។



- សូមអនុវត្តតាមផែនការរបស់ប្អូន !

សូមកាត់កាតនេះចេញដើម្បីជាការរំឭកដល់ប្អូនឲ្យបន្តជួយដូចជាព្រះយេស៊ូវ ។



ម្ដាយរបស់ខ្ញុំ ឪពុកខ្ញុំ និងខ្ញុំបានឲ្យភួយទៅកាន់មន្ទីរពេទ្យកុមារមួយកន្លែង ។ បុគ្គលិកមន្ទីរពេទ្យបាននិយាយថា ភួយទាំងនេះនឹងជួយកុមារមិនឲ្យមានអារម្មណ៍ភ័យខ្លាចទៀតឡើយ ។ ខ្ញុំសប្បាយចិត្តដែលភួយរបស់យើងនឹងជួយលើកទឹកចិត្តក្មេង។ ហើយធ្វើឲ្យពួកគេសប្បាយចិត្ត ។ វាបានធ្វើឲ្យខ្ញុំមានអារម្មណ៍សប្បាយរីករាយផងដែរ ។

**ប្រ៊ុគ្លីន ឌី អាយុ ៩ ឆ្នាំ រដ្ឋតិចសាស ស.រ.អា.**

តើប្អូនកំពុងតែព្យាយាមជួយអ្នកដទៃដូចជាព្រះយេស៊ូវបានធ្វើដោយរបៀបណា ? សូមសរសេរ ហើយប្រាប់មកពួកយើង ។